# ប្រកាសអំពីការអនុវត្តន៍សិទ្ធិឯកជន

សេចក្តីប្រកាសរួមអំពីការអនុវត្តន៍សិទ្ធិឯកជន (ប្រកាស) រៀបរាប់ប្រាប់អំពីរបៀបដែលគេអាចនឹងប្រើ និងបើកចំហព័ត៌មានសុខភាពអំពីអ្នក និងរបៀបដែលអ្នកអាចមានសិទ្ធិពិនិត្យមើលព័ត៌មាននេះបាន។ សូមពិនិត្យមើលវាដោយយកចិត្តទុកដាក់ជាទីបំផុត។ ប្រកាសនេះកំពុងទទួលបានការផ្សព្វផ្សាយដល់អ្នកក្នុងនាមជាអ្នកផ្តល់សេវាសុខភាពនិងសេវា(អ្នកផ្តល់) (**Providence Health & Services (Providence)**), បុគ្គលិកវេជ្ជសាស្ត្រ និងក្រុមគ្រូពេទ្យតំហែទាំសុខភាពផ្សេងទៀត (ដែលជារួមយោងដល់ពាក្យថា៖ "យើងខ្ញុំ" ឬ "របស់យើងខ្ញុំ" ដែលមាននៅក្នុងនេះ)។

## *អ្នកផ្តល់ (**Providence**) មានការសន្យាប្តេជ្ញាចិត្តចំពោះការការពារភាពសម្ងាត់នៃព័ត៌មានសុខភាពរបស់អ្នក*

ច្បាប់តម្រូវឲ្យយើងខ្ញុំរក្សាការពារសិទ្ធិឯកជនដែលទាក់ទងនឹងព័ត៌មានសុខភាព (ដែលតាមធម្មតាត្រូវបានគេហៅថា PHI ព័ត៌មានសុខភាព) ដែលរួមមាន PHI ក្នុងទម្រង់អេឡិចត្រូនិក។ លើសពីនេះ យើងខ្ញុំចាំបាច់ត្រូវជូនដំណឹងអ្នកអំពីកាតព្វកិច្ចស្របច្បាប់ និងការអនុវត្តន៍សិទ្ធិឯកជនរបស់យើងខ្ញុំដែលទាក់ទងទៅនឹងព័ត៌មានសុខភាពរបស់អ្នក និងអនុវត្តតាមប្រកាសនេះ ក្នុងករណីបញ្ញត្តិច្បាប់ច្បាស់លាស់ជាច្រើនទៀតដែលមិនអនុវត្តបាន។ ប្រកាសនេះអនុវត្តចំពោះមធ្យោបាយ, សេវាកម្ម, និងកម្មវិធីរបស់អ្នកផ្តល់ (Providence) ទាំងអស់ដែលផ្តល់សេវាតំហែទាំសុខភាពដល់អ្នក។

## សំណើអនុវត្តន៍ប្រកាសនេះ

ការអនុវត្តន៍សិទ្ធិឯកជនចំពោះព័ត៌មានដែលបានរៀបរាប់ប្រាប់នៅក្នុងប្រកាស នេះត្រូវមានការអនុវត្តតាមដោយ:

- អ្នកអាជីពតំណែទាំសុខភាពណាមួយដែលព្យាបាលអ្នកនៅកន្លែងណាមួយ របស់យើងខ្ញុំ។
- គ្រប់មធ្យោបាយ (មន្ទីរព្យាបាល), ផ្នែក, អង្គភាពដែលមានជាអាទិ៍: មន្ទីរពេទ្យ, មជ្ឈមណ្ឌលវះកាត់, ការព្យាបាលនៅគេហដ្ឋាន, គ្លីនិក និង សាខាផ្សេងៗទៀត។
- គ្រប់សមាជិកសមាជិកាក្រុមការងារដែលមានជាអាទិ៍: និយោជិត, បុគ្គលិកពេទ្យ (វេជ្ជសាស្រ្ត), សិក្ខាកាម, សិស្សនិស្សិត, អ្នកស្ម័គ្រចិត្ត និង អ្នកផ្សេងៗទៀតដែលស្ថិតក្រោមការត្រួតត្រាដោយផ្ទាល់របស់យើងខ្ញុំ បើ ទោះជាពួកគេទទួលបាន ឬមិនទទួលបានប្រាក់កម្រៃពីយើងខ្ញុំក៏ដោយ។
- គ្រូពេទ្យតំណែទាំសុខភាពដទៃៗទៀតដែលបានយល់ព្រមអនុវត្តតាម ប្រកាសស្តីពីការអនុវត្តន៍សិទ្ធិឯកជននេះ។

ប្រកាសនេះផ្តល់នូវព័ត៌មានពិស្តារអំពីរបៀបដែលយើងខ្ញុំអាចនឹងប្រើ និង បើកចំហព័ត៌មានសុខភាពអ្នកដោយមាន ឬមិនមានការអនុញ្ញាតត្រឹមត្រូវក៏ដូច ជាព័ត៌មានច្រើនទៀតអំពីសិទ្ធិជាក់លាក់របស់អ្នកដោយគោរពទៅតាមព័ត៌មាន សុខភាពរបស់អ្នក។

## *ការប្រើប្រាស់ និងបើកចំហព័ត៌មានសុខភាពរបស់អ្នកដែលយើងខ្ញុំអាចនឹងធ្វើ ឡើងដោយគ្មានការអនុញ្ញាតរបស់អ្នក*

**ដើម្បីទាក់ទងអ្នកបាន:** គេអាចនឹងប្រើព័ត៌មានអ្នកដើម្បីទាក់ទងរំឭកអ្នកអំពី ការណាត់ជួប, ផ្តល់នូវលទ្ធផលធ្វើតេស្ត (ពិសោធន៍), ប្រាប់អ្នកអំពីជម្រើស

ព្យាបាល ឬណែនាំប្រាប់អ្នកអំពីអត្ថប្រយោជន៍ និងសេវាកម្មដែលទាក់ទងនឹងបញ្ហាសុខភាពផ្សេងៗទៀត។

**ការព្យាបាល:** គេអាចចែករំលែកព័ត៌មានអ្នកជាមួយនឹងគ្រូពេទ្យតំហែទាំសុខភាពដែលកំពុងផ្តល់នូវសេវាកម្មតំហែទាំសុខភាពដល់អ្នក។ ចំណុចរួមមានការសម្របសម្រួលលើតំហែទាំរបស់អ្នកដោយមិនចាំបាច់មានគ្រូពេទ្យតំហែទាំសុខភាពដទៃៗទៀត និងផ្តល់ការបញ្ជូនទៅកាន់គ្រូពេទ្យតំហែទាំសុខភាពផ្សេងៗទៀត។ ឧទាហរណ៍នៃគ្រូពេទ្យតំហែទាំសុខភាពនានាដែលអាចនឹងចាំបាច់ត្រូវការព័ត៌មានអ្នកដើម្បីព្យាបាលអ្នកនោះមានជាអាទ៍: វេជ្ជបណ្ឌិត, ឱសថការី, គិលានុបដ្ឋាក/យិកា, និងគ្រូពេទ្យតំហែទាំសុខភាពផ្សេងៗទៀតដែលមានប្រភេទដូចជា គ្រូពេទ្យព្យាបាលដោយប្រើចលនា, គ្រូពេទ្យតំហែទាំសុខភាពនៅគេហដ្ឋាន និងអ្នកបច្ចេកទេសខាងថតកាំរស្មីអ៊ិច (x-ray)។ យើងខ្ញុំអាចចែករំលែកព័ត៌មានអ្នកតាមប្រព័ន្ធអេឡិចត្រូនិក ជាមួយនឹងក្រុមគ្រូពេទ្យតំហែទាំសុខភាពរបស់អ្នកប្រយោជន៍ធ្វើឲ្យប្រាកដថាពួកគេទទួលបានព័ត៌មានអ្នកភ្លាមៗតាមដែលអាចធ្វើទៅបានដើម្បីព្យាបាលអ្នក។

យើងខ្ញុំអាចនឹងចែករំលែកព័ត៌មានសុខភាពអ្នកជាមួយនឹងសមាជិកក្រុមគ្រួសារ ឬមិត្តភ័ក្រ្តណាមួយដែលទទួលបានការអនុញ្ញាតឲ្យចូលរួមក្នុងការជួយដល់គ្រូពេទ្យតំហែទាំសុខភាពអ្នក។ យើងខ្ញុំត្រូវធ្វើដូច្នោះតែក្នុងករណីដែលអ្នកយល់ស្រប ឬមិនយល់ទាស ហើយនឹងគ្រាន់តែចែករំលែកពួកគេនូវព័ត៌មានដែលពួកគេចាំបាច់ត្រូវការដើម្បីជួយដល់អ្នកប៉ុណ្ណោះ។ បើអ្នកមិនអាចយល់ស្រប និងយល់ទាសចំពោះការបើកចំហាមួយប្រភេទនេះ យើងខ្ញុំអាចនឹងបើកចំហាព័ត៌មានសុខភាពអ្នកនៅពេលដែលមានករណីសំខាន់ចាំបាច់ដែលយើងខ្ញុំត្រូវកំណត់ថា វាស្ថិតនៅក្នុងផលប្រយោជន៍ល្អបំផុតរបស់អ្នកលើ

មូលដ្ឋានវាយតម្លៃតាមលក្ខណៈវិជ្ជាជីវៈរបស់យើងខ្ញុំ។ យើងខ្ញុំអាចនឹងបើកចំហព័ត៌មានសុខភាពប្រាប់ទៅសមាជិកក្រុមគ្រួសារ, បងប្អូន, ឬមនុស្សម្នាក់ទៀតដែលពេលនោះទទួលបានការអនុញ្ញាតឲ្យចូលរួមពាក់ព័ន្ធក្នុងបញ្ហាតំហែទាំសុខភាព ឬការទូទាត់របស់អ្នកសម្រាប់ថ្លៃតំហែទាំសុខភាពនៅពេលដែលអ្នកទទួលមរណៈភាព ក្នុងករណីដែលមិនច្បាស់លាស់ជាមួយនឹងការនិយមចង់ ឬចំណូលចិត្តដែលបង្ហាញជាអាទិភាពរបស់អ្នក។

**ការទូទាត់ថ្លៃសាវា:** ដើម្បីទទួលបានការទូទាត់ថ្លៃសេវាកម្មតំហែទាំសុខភាពអ្នក យើងខ្ញុំអាចនឹងត្រូវផ្តល់នូវព័ត៌មានតំហែទាំសុខភាពទៅឲ្យភាគីដែលទទួលខុសត្រូវចំពោះបង់ប្រាក់។ បញ្ហានេះអាចនឹងរួមមានតំហែទាំផ្នែកវេជ្ជសាស្ត្រ (Medicare), ជំនួយផ្នែកពេទ្យ (Medicaid) (គម្រោងសុខភាពរបស់រដ្ឋ) ឬក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក។ ក្រុមហ៊ុនធានារ៉ាប់រង ឬគម្រោងសុខភាពរបស់អ្នកអាចនឹងចាំបាច់ត្រូវការព័ត៌មានអ្នកសម្រាប់សកម្មភាពនានាដែលមានប្រភេទដូចជាការកំណត់សិទ្ធិទទួលបានការរ៉ាប់រងរបស់អ្នក, ការពិនិត្យវាយតម្លៃលើភាពសំខាន់ផ្នែកពេទ្យនៃសេវាតំហែទាំសុខភាពដែលបានផ្តល់ឲ្យអ្នក ឬការផ្តល់ការបញ្ជាក់យល់ព្រមចំពោះសេវាកម្ម ឬស្នាក់នៅមន្ទីរពេទ្យ។

**ប្រតិបត្តិការតំហែទាំសុខភាព:** ព័ត៌មានសុខភាពអ្នកអាចនឹងត្រូវបានគេប្រើប្រាស់ដើម្បីគាំទ្រសកម្មភាពការងារយើងខ្ញុំ និងដើម្បីធានាឲ្យបានពិតប្រាកដថា កំពុងមានការផ្តល់នូវសេវាតំហែទាំសុខភាពដោយគុណភាពខ្ពស់។ សកម្មភាពមួយចំនួនមានជាអាទិ៍: ការវាយតម្លៃលើគុណភាព, ការពិនិត្យវាយតម្លៃលើនិយោជិត ឬមិត្តរួមការងារ, ការបណ្តុះបណ្តាលបុគ្គលិកពេទ្យ, អ្នកទទួល ឬការផ្តល់សញ្ញាប័ត្រ, ការប្រមូល និងត្រួតពិនិត្យព័ត៌មានរបស់ទីភ្នាក់ងារអនុវត្តន៍ច្បាប់។

យើងខ្ញុំអាចនឹងចែករំលែកព័ត៌មានអំពីសុខភាពបានការពារ (PHI) របស់អ្នកជាមួយនឹងភាគីទីបីនានាដែលផ្តល់សេវាកម្មដែលមានប្រភេទដូចជា ការកត់ត្រា ឬការធ្វើវិក្កយបត្រ។ ស្ថិតក្នុងករណីអស់ទាំងនោះ យើងខ្ញុំមានកិច្ចសន្យាព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរជាមួយនឹងភាគីទីបីនានាដែលពួកគេនឹងមិនប្រើ ឬបើកចំហាព័ត៌មានសុខភាពអ្នក វៀរលែងតែក្នុងករណីដែលមានការអនុញ្ញាតដោយច្បាប់។

លើសពីនេះ យើងខ្ញុំអាចនឹងប្រើព័ត៌មានអ្នក (ឈ្មោះ, អាសយដ្ឋាន, ថ្ងៃខែឆ្នាំកំណើត, ផ្នែកសេវាកម្ម, គ្រូពេទ្យព្យាបាល, កាលបរិច្ឆេទព្យាបាល, លទ្ធផល) សម្រាប់បម្រើឲ្យសកម្មភាពកៀងគរថវិកា។ **អ្នកមានសិទ្ធិបដិសេធចំពោះការទទួលសារទំនាក់ទំនងប្រភេទអស់ទាំងនេះ។** បើអ្នកមិនចង់ទទួលបាននូវឯកសារទាំងនេះទេនោះ សូមមេត្តាទាក់ទងការិយាល័យមូលនិធិយើងខ្ញុំ ហើយស្នើកុំឲ្យគេផ្ញើឯកសារទាំងនេះឲ្យអ្នក។

បើអ្នកមិនយល់ទាស់ទេនោះ ឈ្មោះ និងទីកន្លែងអ្នកអាចនឹងមានការបញ្ចូលគ្នានៅបញ្ជីឈ្មោះ (ដាយរិកតូរី) អ្នកជម្ងឺរបស់យើងខ្ញុំបាន។ ក្នុងករណីដែលមានការបញ្ចូលវា យើងខ្ញុំនឹងគ្រាន់តែចែករំលែកព័ត៌មានដ៏តិចតួចបំផុតប៉ុណ្ណោះអំពីអ្នក (ដែលមានប្រភេទដូចជាទីកន្លែងអ្នកនៅមន្ទីរពេទ្យមួយ និងស្ថានភាពទូទៅ) ជាមួយនឹងមនុស្សទាំងឡាយណាដែលសាកសួរអំពីឈ្មោះអ្នក។ បើអ្នកសម្រេចប្រាប់អំពីការជាប់ទាក់ទងសាសនារបស់អ្នក ហើយមិនយល់ទាសទេនោះ យើងខ្ញុំអាចនឹងប្រាប់ឈ្មោះ និងលេខបន្ទប់អ្នកទៅអាចារ្យដែលមកពីសហាគមន៍ជំនឿសាសនារបស់អ្នក

ប្រកាសនេះក៏រៀបរាប់ផងដែរនូវការអនុវត្តន៍សិទ្ធិឯកជនលើការរៀបចំចាត់ចែងតំហែទាំសុខភាព ("OHCA") រវាងយើងខ្ញុំ និងក្រុមគ្រូពេទ្យ និងអង្គការតំហែទាំ

សុខភាពដែលមានសិទ្ធិពិតប្រាកដ។ OHCA អនុញ្ញាតឲ្យមាននីតិបុគ្គលដែលទទួលបានការធានារ៉ាប់រងស្របច្បាប់ដាច់ៗពីគ្នាប្រើ និងបើកចំហ PHI សម្រាប់ប្រតិបត្តិការរៀបចំចាត់ចែងរួមគ្នាបាន។ យើងខ្ញុំរំពឹងលើការរៀបចំប្រភេទនេះរបស់អង្គការតំហែទាំសុខភាពដែលបានយល់ព្រមធ្វើការងារជាមួយគ្នាទៅវិញទៅមក ដើម្បីសម្របសម្រួលលទ្ធភាពប្រើប្រាស់ព័ត៌មានសុខភាពដែលសំខាន់ជាប់ទាក់ទងទៅនឹងបញ្ហាតំហែទាំសុខភាព ឬការព្យាបាលរបស់អ្នក។ ឧទាហរណ៍ បើអ្នកមានវត្តមាននៅមន្ទីរពេទ្យសម្រាប់ការព្យាបាលសង្គ្រោះបន្ទាន់ ហើយមិនអាចប្រាប់ព័ត៌មានសំខាន់ៗអំពីសុខភាពអ្នកបាន OHCA អនុញ្ញាតឲ្យយើងខ្ញុំប្រើប្រាស់ PHI របស់អ្នកដែលបានពីក្រុមអ្នកចូលរួម OHCA របស់យើងខ្ញុំដើម្បីព្យាបាលអ្នក។ នៅពេលដែលគេចាំបាច់ត្រូវការវា លទ្ធភាពស្រេចបាច់ចំពោះការប្រើ PHI អ្នក មានន័យសំដៅដល់ការព្យាបាលកាន់តែប្រសើរឡើងចំពោះអ្នក។ យើងខ្ញុំរក្សាទុកព័ត៌មានសុខភាពអំពីអ្នកជម្ងឺយើងខ្ញុំនៅក្នុងកំណត់ត្រាសុខភាពរួមតាមប្រព័ន្ធអេឡិចត្រូនិកជាមួយនឹងឈ្មោះគ្រូពេទ្យតំហែទាំសុខភាពផ្សេងៗទៀតដែលចូលរួមក្នុង OHCA នេះ។ អ្នកផ្តល់ (Providence) និងសមាជិកសមាជិការបស់ OHCA ត្រូវតែអាចចែករំលែកព័ត៌មានសុខភាពដោយសេរី ឬឥតគិតថ្លៃសម្រាប់គោលបំណងនៃការព្យាបាលជម្ងឺ, ការទូទាត់ និងប្រតិបត្តិការតំហែទាំសុខភាព។ សម្រាប់ហេតុផលនេះហើយដែលយើងខ្ញុំបានបង្កើតឲ្យមាន OHCA និងប្រកាសរួមនេះឡើង។ សមាជិកសមាជិកា OHCA អាចនឹងសម្រេចទទួលបាននូវកំណត់សម្គាល់ផ្ទាល់ខ្លួនរបស់ពួកគេបាន។ សម្រាប់ព័ត៌មានអំពីអង្គការនានាដែលបានចូលរួមក្នុង OHCA របស់យើងខ្ញុំ សូមមេត្តាទាក់ទងការិយាល័យទទួលបន្ទុកសិទ្ធិឯកជនដែលមានចុះក្នុងប្រកាសនេះ។

## *ការប្រើប្រាស់ និងការបើកចំហផ្សេងៗទៀតដែលយើងខ្ញុំអាចនឹងធ្វើឡើងដោយ<u>មិនចាំបាច់មាន</u>ការអនុញ្ញាតិរបស់អ្នក*

មានវិធីមួយចំនួនដែលព័ត៌មានសុខភាពអ្នកអាចត្រូវបានគេប្រើ ឬបើកចំហដោយមិនចាំបាច់មានការអនុញ្ញាតិរបស់អ្នក។ ជាទូទៅ ការប្រើប្រាស់ និងការបើកចំហទាំងនេះមានទាំងតម្រូវការចាំបាច់ត្រូវធ្វើឡើងដោយច្បាប់ទាំងសម្រាប់គោលបំណងសុខភាព និងសុវត្ថិភាពសាធារណៈ។

**នៅពេលដែលមានតម្រូវចាំបាច់ដោយច្បាប់:** យើងខ្ញុំអាចនឹងប្រើ ឬបើកចំហព័ត៌មានសុខភាពអ្នកនៅពេលដែលមានតម្រូវការចាំបាច់ដោយច្បាប់។ បើករណីនេះកើតមានឡើង យើងខ្ញុំនឹងអនុវត្តតាមច្បាប់ ហើយនឹងគ្រាន់តែបើកចំហព័ត៌មានដែលសំខាន់ចាំបាច់ប៉ុណ្ណោះ។

**សុខភាពសាធារៈ:** យើងខ្ញុំអាចនឹងបើកចំហព័ត៌មានសុខភាពរបស់អ្នកប្រាប់ទៅអាជ្ញាធរទទួលបន្ទុកសុខភាពសាធារណៈដើម្បីសកម្មភាពសុខភាពសាធារណៈ។ សកម្មភាពសុខភាពសាធារណៈមានជាអាទិ៍: ការបង្ការ ឬត្រួតពិនិត្យជម្ងឺ, របួសស្នាម, ពិការភាព, និងការឆ្លើយតបទៅនឹងរបាយការណ៍រំលោភបំពាន, ការមិនយកចិត្តទុកដាក់ ឬអំពើហិង្សាក្នុងគ្រួសារ។ យើងខ្ញុំអាចនឹងបើកចំហព័ត៌មានសុខភាពរបស់អ្នកប្រាប់ទៅមនុស្ស ឬទីភ្នាក់ងារមួយដែលត្រូវរាយការណ៍អំពីព្រឹត្តិការណ៍មិនល្អ, ការបាក់បែក ឬបញ្ហាផលិតផលកម្មវិធី, ការប្រែប្រួលខុសប្រក្រតីនៃជីវៈផលិតផល, ឬសម្រាប់ការហៅឲ្យយកផលិតផលត្រឡប់ទៅវិញ, ការជួសជុល ឬការដោះដូរថ្មី។ ការបើកចំហព័ត៌មានមួយចំនួននៃសភាពបែបនេះនឹងមានការធ្វើឡើងដោយច្បាស់លាស់ដោយប្រើច្បាប់រដ្ឋ និងសហព័ន្ធ។

**ការមើលថែសុខភាព:** យើងខ្ញុំអាចនឹងបើកចំហព័ត៌មានសុខភាពរបស់អ្នកប្រាប់ទៅទីភ្នាក់ងារ ឬក្រសួងត្រួតត្រាផ្នែកសុខភាពសម្រាប់សកម្មភាពត្រួតពិនិត្យដែលទទួលបានការអនុញ្ញាតិដោយច្បាប់ដែលមានប្រភេទដូចជា ការត្រួតពិនិត្យ (សនវកម្ម), ការស៊ើបអង្កេត, និងការធ្វើអធិការកិច្ច។ ទីភ្នាក់ងារត្រួតពិនិត្យខាងសុខភាពមានជាអាទ៏: ក្រសួងនានារបស់រដ្ឋាភិបាលដែលមើលការខុសត្រូវប្រព័ន្ធគ្រប់គ្រងតំហែទាំសុខភាព, កម្មវិធីអត្ថប្រយោជន៍រដ្ឋាភិបាល, កម្មវិធីនិយតកម្មនៃរដ្ឋាភិបាល និងសិទ្ធិជនស៊ីវិល។

**បណ្ដឹងផ្លូវច្បាប់:** យើងខ្ញុំអាចនឹងប្រើ ឬបើកចំហព័ត៌មានសុខភាពអ្នកក្នុងការឆ្លើយតបទៅនឹងបញ្ជា ឬបង្គាប់ជាផ្លូវការ ឬរបស់តុលាកាតាមបណ្ដឹងផ្លូវការ ឬតាមតុលាការ, ឬក្នុងការឆ្លើយតបទៅនឹងដីកាកោះមួយ, របាយការណ៍ស្ដីពីគំហើយញ ឬនីតិវិធីច្បាប់។

**ការអនុវត្តន៍ច្បាប់:** យើងខ្ញុំអាចនឹងប្រើ ឬបើកចំហព័ត៌មានសុខភាពអ្នកសម្រាប់គោលបំណងអនុវត្តន៍ច្បាប់បាន។ ឧទាហរណ៍នានាមានជាអាទ៏: (1) ការឆ្លើយតបទៅនឹងនីតិវិធីច្បាប់; (2) ការផ្ដល់ព័ត៌មានមានកម្រិតដើម្បីកំណត់អត្តសញ្ញាណ ឬរកមុខសញ្ញាជនសង្ស័យ; (3) ការផ្ដល់ព័ត៌មានអំពីជនរងគ្រោះពីឧក្រិដ្ឋកម្ម; (4) ការរាយការណ៍អំពីការសង្ស័យដែលថា ការស្លាប់នោះបានកើតបានឡើងដោយសារការប្រព្រឹត្តបទឧក្រិដ្ឋ; (5) ការរាយការណ៍អំពីឧក្រិដ្ឋកម្មដែលបានកើតឡើងនៅបរិវេណរបស់យើងខ្ញុំ; និង (6) សម្រាប់ការសង្គ្រោះបន្ទាន់ផ្នែកពេទ្យ, ការរាយការណ៍ករណីដែលបង្ហាញឲ្យថាពិតជាមានឧក្រិដ្ឋកម្មមួយបានកើតមានឡើង។

**ការទប់ស្កាត់ដល់ការគម្រាមកម្ហែងធ្ងន់ធ្ងរ:** យើងខ្ញុំអាចនឹងប្រើ ឬបើកចំហព័ត៌មានសុខភាពអ្នកបាន បើយើងខ្ញុំជឿជាក់យ៉ាងមុតមាំថា ការប្រើ ឬបើកចំហ

នេះមានសារៈសំខាន់ចាំបាច់ត្រូវទប់ស្កាត់ ឬកាត់បន្ថយបញ្ហាគម្រាមកំហែងធ្ងន់ធ្ងរដែលជិតនឹងប៉ះពាល់ដល់សុវត្ថិភាព និងសុខភាពរបស់បុគ្គល ឬសាធារណៈជន។ គេអាចគ្រាន់តែធ្វើការបើកចំហព័ត៌មានប្រាប់ដល់បុគ្គលម្នាក់ដែលមានលក្ខណៈសមស្របអាចនឹងទប់ស្កាត់ ឬកាត់បន្ថយការគម្រាមកំហែងបានប៉ុណ្ណោះ។

**ប៉ូលីសខាងសពវិភាគ, អ្នកចាត់ចែងធ្វើឈាបនកិច្ចសព, និងការបរិច្ចាកសរីរាង្គ:** យើងខ្ញុំអាចនឹងបើកចំហព័ត៌មានសុខភាពអ្នកប្រាប់ទៅប៉ូលីសខាងសពវិភាគ ឬអ្នកពិនិត្យផ្នែកវេជ្ជសាស្ត្រសម្រាប់គោលបំណងកំណត់អត្តសញ្ញាណ, ការកំណត់មូលហេតុនៃការស្លាប់ ឬកាតព្វកិច្ចដែលតម្រូវឲ្យមានជាចាំបាច់តាមលក្ខណៈច្បាប់ផ្សេងៗទៀត។ យើងខ្ញុំអាចនឹងបើកចំហព័ត៌មានសុខភាពអ្នកប្រាប់ទៅអ្នកចាត់ចែងធ្វើឈាបនកិច្ចសពប្រយោជន៍អនុញ្ញាតឲ្យគាត់បំពេញកាតព្វកិច្ចរបស់គាត់បាន។ យើងខ្ញុំអាចនឹងបើកចំហព័ត៌មានអ្នកដើម្បីសម្របសម្រួលលើការបរិច្ចាកសរីរាង្គ, ភ្នែក ឬ សន្ធាន។

**ការសិក្សាស្រាវជ្រាវ:** យើងខ្ញុំអាចនឹងបើកចំហព័ត៌មានសុខភាពអ្នកប្រាប់ទៅក្រុមអ្នកសិក្សាស្រាវជ្រាវបាន ឲ្យតែថាការសិក្សាស្រាវជ្រាវនោះទទួលបានការអនុញ្ញាតត្រឹមត្រូវពីសំណាក់ក្រុមប្រឹក្សាត្រួតពិនិត្យវាយតម្លៃស្ថាប័ន និង/ឬក្រុមប្រឹក្សាទទួលបន្ទុកសិទ្ធិឯកជន, និងពិធីសារសិក្សាស្រាវជ្រាវត្រឹមត្រូវដែលទទួលបានការបញ្ជាក់យល់ព្រមឲ្យធានាដល់សិទ្ធិឯកជនរបស់អ្នក។ យើងខ្ញុំអាចនឹងបើកចំហព័ត៌មានសុខភាពអំពីអ្នកប្រាប់អ្នករៀបចំអនុវត្តន៍គម្រោងការណ៍សិក្សាស្រាវជ្រាវមួយ។

**សកម្មភាពយោធា និងសន្តិសុខជាតិ:** យើងខ្ញុំអាចនឹងបើកចំហព័ត៌មានសុខភាពរបស់បុគ្គលិកកងទ័ពបាន: (1) សម្រាប់សកម្មភាពដែលមានការចាត់ទុកថា

សំខាន់ចាំបាច់ដោយក្រុមអាជ្ញាធរជាមេបញ្ជាការយោធាដែលមានសមត្ថកិច្ចត្រឹមត្រូវ; (2) សម្រាប់គោលបំណងកំណត់របស់សិទ្ធិទទួលបានអត្ថប្រយោជន៍របស់ក្រសួងកិច្ចការអតីតយុទ្ធជន; ឬ (3) ប្រាប់ទៅអាជ្ញាធរ ឬរដ្ឋអំណាចយោធាបរទេស ក្នុងករណីដែលអ្នកជាសមាជិកសមាជិកាដែលស្ថិតក្នុងកាតព្វកិច្ចយោធាប្រទេសនោះ។ លើសពីនេះ យើងខ្ញុំអាចនឹងបើកចំហព័ត៌មានសុខភាពអ្នកប្រាប់ក្រុមមន្ត្រីសហព័ន្ធដែលទទួលបានការអនុញ្ញាតត្រឹមត្រូវដើម្បីអនុវត្តសកម្មភាពការពារសន្តិសុខជាតិ និង ស៊ើបការណ៍ដែលមានជាអាទិ៍: បញ្ញត្តិច្បាប់ស្ដីពីផ្នែកការពារប្រធានាធិបតី ឬអ្នកផ្សេងៗទៀតដែលទទួលបានការអនុញ្ញាតជាផ្លូវការឲ្យទទួលបានព័ត៌មាន។

**អ្នកទោស/ជនដែលគេចាប់ខ្លួនបាន**: យើងខ្ញុំអាចប្រើ ឬបើកចំហព័ត៌មានសុខភាពអ្នកប្រាប់ទៅមន្ត្រីនៃស្ថាប័នកែប្រែ ឬអនុវត្តន៍ច្បាប់ បើអ្នកជាអ្នកទោសនៃមណ្ឌលកែប្រែ ឬស្ថិតក្នុងនោះ ហើយព័ត៌មានដែលសំខាន់ចាំបាច់ត្រូវព្យាបាលអ្នក ឬការពារសុខភាព និងសុវត្ថិភាពរបស់អ្នក, អ្នកទោសដទៃទៀត, និយោជិតនៅមណ្ឌលកែប្រែ ឬកន្លែងផ្សេងៗទៀត។

**សំណង ឬតម្លៃជួសជុលរបស់បុគ្គលិកកម្មករ**: យើងខ្ញុំអាចនឹងប្រើ ឬបើកចំហព័ត៌មានសុខភាពអ្នកតាមដែលចាំបាច់ដើម្បីអនុវត្តាមច្បាប់ស្ដីពីសំណង ឬតម្លៃជួសជុលរបស់បុគ្គលិកកម្មករ និងកម្មវិធីផ្សេងៗទៀតដែលបានបង្កើតឡើងជាផ្លូវការ។

**ជំនួយ ឬការជួសជុលមហន្តរាយ**: យើងខ្ញុំអាចនឹងបើកចំហព័ត៌មានសុខភាពអំពីអ្នកប្រាប់នីតិបុគ្គលដែលកំពុងជួយក្នុងកិច្ចខិតខំប្រឹងប្រែងជួសជុលមហន្តរាយដើម្បីឲ្យក្រុមគ្រួសារ និង មិត្តភ័ក្ត្រអ្នកអាចទទួលបានការជូនដំណឹងអំពីលក្ខខណ្ឌ, ស្ថានភាព, និងទីកន្លែងរបស់អ្នក។

## ការប្រើប្រាស់ និងបើកចំហព័ត៌មានសុខភាពរបស់អ្នកដែលយើងខ្ញុំអាចនឹងធ្វើឡើងដោយមានការអនុញ្ញាតរបស់អ្នក

ការប្រើ និង បើកចំហព័ត៌មានសុខភាពពិតប្រាកដរបស់អ្នកដែលមានជាអាទ៍: ការរកទីផ្សារលក់, ការលក់ព័ត៌មានសុខភាព ឬ ការប្រកាសចេញកំណត់សម្គាល់អំពីការព្យាបាលផ្នែកចិត្តសាស្រ្តនឹងគ្រាន់តែទទួលបានការធ្វើឡើងដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នកប៉ុណ្ណោះ។ អ្នកអាចនឹងបដិសេធការអនុញ្ញាតមួយជាលាយលក្ខណ៍អក្សរនៅពេលណាមួយបាន លើកលែងតែចំពោះវិលាភាពដែលយើងខ្ញុំបានចាត់ការណ៍រួចហើយដោយអាស្រ័យលើការអនុញ្ញាតនេះ។

ការប្រើ និង បើកចំហាដែលមានការបរិយាយផ្សេងពីនៅក្នុងប្រកាសនេះនឹងគ្រាន់តែទទួលបានការធ្វើឡើងជាមួយនឹងការអនុញ្ញាតជាលាយលក្ខណ៍របស់អ្នកប៉ុណ្ណោះ។

ច្បាប់សហព័ន្ធ និង រដ្ឋអាចនឹងកម្រិតលក្ខខណ្ឌបន្ថែមទៀតលើការបើកចំហប្រាប់អំពីព័ត៌មានសុខភាពអ្នកសម្រាប់កម្មវិធីព្យាបាលបន្សាបថ្នាំញៀន ឬ ជាតិសុរា, កម្មវិធីព្យាបាលជម្ងឺឆ្លងតាមផ្លូវភេទ, ឬសុខភាពផ្លូវចិត្ត។ នៅពេលមានតម្រូវការចាំបាច់ដោយច្បាប់ យើងខ្ញុំនឹងសុំការអនុញ្ញាតរបស់អ្នកសិន មុននឹងចេញប្រកាសព័ត៌មានប្រភេទនេះ។

## *សិទ្ធិរបស់អ្នក*

**សិទ្ធិស្នើសុំកម្រិតលក្ខខណ្ឌ:** អ្នកមានសិទ្ធិសុំឲ្យយើងខ្ញុំដាក់កម្រិតលក្ខខណ្ឌលើវិធីដែលយើងខ្ញុំប្រើ ឬបើកចំហាព័ត៌មានសុខភាពអ្នកសម្រាប់ការព្យាបាល, ការទូទាត់, ឬប្រតិបត្តិការតំហែទាំសុខភាព។ យើងខ្ញុំនឹងពិនិត្យសម្រេចលើ

សំណើអ្នក តែមិនចាំបាច់ត្រូវយល់ព្រមចំពោះការកម្រិតលក្ខខណ្ឌនេះទេ (វៀរលែងតែមានរៀបរាប់ខាងក្រោម)។ បើអ្នកយល់ព្រមចំពោះការកម្រិតលក្ខខណ្ឌមួយ យើងខ្ញុំនឹងមិនប្រើ ឬបើកចំហាព័ត៌មានសុខភាពអ្នកដោយស្ថិតក្នុងការរំលោភបំពានលើកម្រិតលក្ខខណ្ឌនោះទេ បើវាគ្មានតម្រូវការចាំបាច់សម្រាប់ការព្យាបាលសង្គ្រោះបន្ទាន់។ បើការកម្រិតលក្ខខណ្ឌលែងមានលទ្ធភាពធ្វើទៅបាន យើងខ្ញុំនឹងជូនដំណឹងដល់អ្នក។

**សិទ្ធិកម្រិតលក្ខខណ្ឌការបើកចំហាព័ត៌មានប្រាប់ទៅកម្មវិធីសុខភាពនានា:** អ្នកអាចនឹងស្នើសុំជាលាយលក្ខណ៍អក្សរ (នៅពេលកំពុងទទួលបានអត្ថប្រយោជន៍) កុំឲ្យយើងខ្ញុំបើកចំហាព័ត៌មានប្រាប់ទៅកម្មវិធីសុខភាពនានាដែលអ្នកបានបង់ប្រាក់ឲ្យមុខចំណាយ ឬសេវាកម្មនានាដោយខ្លួនអ្នកផ្ទាល់។ យើងខ្ញុំត្រូវតែយល់ព្រមមិនបើកចំហាព័ត៌មាននេះប្រាប់ទៅកម្មវិធីសុខភាពរបស់អ្នក បើមានការឆ្លើយតបទៅនឹងលក្ខខណ្ឌពិតប្រាកដនានា។

**ការប្រាស្រ័យទាក់ទងជាសម្ងាត់:** យើងខ្ញុំនឹងដាក់សំណើសមស្របទៅអ្នក អំពីព័ត៌មានសុខភាពរបស់អ្នកតាមវិធីផ្សេងៗ ឬទីកន្លែងតាមជម្រើស។ ឧទាហរណ៍ បើអ្នកទទួលបានការរ៉ាប់រងលើគម្រោងសុខភាពមួយ តែមិនមែនជាអ្នកចុះឈ្មោះជាវសេវាកម្ម ហើយចង់ឲ្យគេផ្ញើព័ត៌មានសុខភាពអ្នកទៅកាន់អាសយដ្ឋានផ្សេងជំនួសឲ្យអាសយដ្ឋានអ្នកចុះឈ្មោះជាវសេវាកម្ម តាមធម្មតា យើងខ្ញុំអាចដោះស្រាយបញ្ហានោះឲ្យអ្នកបាន។

**ការជូនដំណឹងប្រាប់អំពីកំហុស:** អ្នកមានសិទ្ធិទទួលបានការជូនដំណឹងអំពីកំហុសនានាលើបញ្ហាព័ត៌មានសុខភាពរបស់អ្នកដូចដែលមានតម្រូវដោយច្បាប់។

**សិទ្ធិ ឬ លទ្ធភាពប្រើប្រាស់ ឬមើលព័ត៌មានសុខភាពអ្នក:** អ្នកមានសិទ្ធិទទួលបានសំណៅព័ត៌មានសុខភាពអ្នកមួយច្បាប់ដែលយើងខ្ញុំថែរក្សាទុកដោយមានការលើកលែងតិចតួចខ្លះៗ។ អ្នកអាចស្នើសុំលទ្ធភាពប្រើប្រាស់ព័ត៌មានសុខភាពអ្នកជាលាយលក្ខណ៍ ហើយអ្នកអាចស្នើសុំសំណៅព័ត៌មានអ្នកជាទម្រង់អេឡិចត្រូនិកបាន។ យើងខ្ញុំសូមរក្សាសិទ្ធិគិតថ្លៃសមស្របមួយសម្រាប់ថ្លៃបង្កើត និងការផ្តល់ព័ត៌មានសុខភាពអ្នក។ អ្នកមានសិទ្ធិស្នើសុំឲ្យគេផ្ញើព័ត៌មានសុខភាពអ្នកទៅឲ្យបុគ្គល ឬនីតិបុគ្គលណាមួយដែលមានប្រភេទដូចជាវេជ្ជបណ្ឌិត, អ្នកមើលថែ ឬ កំណត់ត្រាសុខភាពផ្ទាល់ខ្លួននៅអនឡាញ (លើប្រព័ន្ធអ៊ីនធឺណិត)បាន។

**កំណែប្រែព័ត៌មានសុខភាពរបស់អ្នក:** អ្នកមានសិទ្ធិសុំឲ្យយើងខ្ញុំកែប្រែព័ត៌មានសុខភាពណាមួយរបស់អ្នកបាន។ អ្នកចាំបាច់ត្រូវស្នើសុំកំណែប្រែនេះជាលាយលក្ខណ៍អក្សរ ហើយដាក់សុំ/បញ្ជូនវាទៅផ្នែកកំណត់ត្រាពេទ្យនៃមន្ទីរព្យាបាលបាន។ យើងខ្ញុំអាចនឹងបដិសេធសំណើអ្នកនៅក្នុងស្ថានភាពពិតប្រាកដនានាដែលមានប្រភេទដូចជាព័ត៌មានសុខភាពដែលមាននៅក្នុងកំណត់ត្រាអ្នកដែលនៅពេលនោះមានការបង្កើតឡើងដោយគ្រូពេទ្យម្នាក់ទៀត ឬ ក្នុងករណីដែលយើងខ្ញុំកំណត់ព័ត៌មានអ្នកថាពិតជាត្រឹមត្រូវ និងពេញលេញ។ ការបដិសេធណាមួយត្រូវមានការធ្វើឡើងជាលាយលក្ខណ៍អក្សរ។ អ្នកមានសិទ្ធិតវ៉ាការបដិសេធរបស់យើងខ្ញុំ ដោយមានការដាក់បណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សរអំពីសេចក្តីប្រកាសបដិសេធមួយច្បាប់។

**ការពន្យល់អំពីការបើកចំហព័ត៌មានពិតប្រាកដ:** អ្នកមានសិទ្ធិចំពោះការចុះនូវការបើកចំហដែលយើងខ្ញុំធ្វើឡើងចំពោះព័ត៌មានសុខភាពរបស់អ្នក វៀរលែងតែសម្រាប់ការបើកចំហទាំងឡាយណាដែលមានការធ្វើឡើងសម្រាប់ការព្យាបាល,

ការទូទាត់, ឬប្រតិបត្តិការតំហែទាំសុខភាព, ឬការបើកចំហទាំងឡាយណាដែលមានការធ្វើឡើងដោយយោងតាមការអនុញ្ញាតត្រឹមត្រូវរបស់អ្នក។ តាមធម្មតាប្រភេទនៃការបើកចំហព័ត៌មាននេះមានផ្ទុកនៅក្នុងការចុះផ្សាយដែលនឹងក្លាយជាការបើកចំហដែលមានការធ្វើឡើងសម្រាប់គោលបំណងសុខភាពសាធារណៈដែលសំខាន់ចាំបាច់, ការអនុវត្តន៍ច្បាប់, បណ្តឹងផ្លូវច្បាប់, ឬ សម្រាប់អ្វីផ្សេងទៀតដែលតម្រូវឲ្យមានសម្រាប់ការរាយការណ៍អំពីប្រភេទសំបុត្រកំណើត និងសំបុត្របញ្ជាក់មរណភាព។

**ការអនុវត្តន៍សិទ្ធិរបស់អ្នក:** ដើម្បីអនុវត្តសិទ្ធិណាមួយខាងលើនេះបាន ឬក្នុងករណីដែលអ្នកចាំបាច់ត្រូវចែករំលែក ឬផ្សព្វផ្សាយព័ត៌មានសុខភាពអ្នកជាមួយ/ទៅមនុស្សម្នាក់សម្រាប់គោលបំណងផ្សេងទៀតលើសពីអ្វីដែលបានចុះនៅកន្លែងនេះ ចូរទាក់ទងផ្នែកកំណត់ត្រាពេទ្យដែលមានសមត្ថកិច្ចត្រឹមត្រូវ។

### *សំណួរ និង បណ្តឹងនានា*

បើអ្នកមានចម្ងល់ ឬកង្វល់ណាមួយនោះអំពីសិទ្ធិឯកជនរបស់អ្នកដែលត្រូវបានគេរំលោភបំពាននោះ សូមមេត្តាទាក់ទងមន្ត្រីទទួលបន្ទុកខាងសិទ្ធិឯកជនរបស់យើងខ្ញុំតាមទូរសព្ទលេខ **1-(800) 628-PROV (800-628-7768)**។ លើសពីនេះ អ្នកមានសិទ្ធិប្តឹងទៅលេខាធិការផ្នែកសុខភាព និងកិច្ចការសង្គមតាមអាសយដ្ឋាន:

**Office for Civil Rights – AK, WA, OR, MT**

U.S. Department of Health and Human Services
2201 Sixth Avenue - M/S: RX-11
Seattle, WA 98121-1831

**Office for Civil Rights – CA**

U.S. Department of Health and Human Services
90 7th Street, Suite 4-100
San Francisco, CA  94103

នឹងមិនមានការសងសឹកប្រឆាំងនឹងអ្នកចំពោះការដាក់បណ្តឹងនេះទេ។

**កំណែប្រែនានាចំពោះប្រកាសរួមអំពីការអនុវត្តន៍សិទ្ធិឯកជន**

យើងខ្ញុំសូមរក្សាសិទ្ធិកែប្រែលក្ខខណ្ឌនៃប្រកាសយើងខ្ញុំនៅពេលណាមួយបាន។ បទបញ្ញត្តិនៃប្រកាសថ្មីនឹងចាប់មានប្រសិទ្ធភាពសម្រាប់ការការពាររាល់ព័ត៌មានសុខភាពដែលយើងខ្ញុំបន្តថែរក្សាទុក។ យើងខ្ញុំអាចនឹងពិនិត្យមើលសំណៅប្រកាសថ្មីបំផុតរបស់យើងខ្ញុំនៅលើវិបសាយរបស់យើងខ្ញុំដែលមានអាសយដ្ឋានអ៊ីនទែរណែត **www.providence.org** ឬស្នើសុំសំណៅថ្មីមួយច្បាប់ពីផ្នែកកំណត់ត្រាពេទ្យ, មន្ត្រីទទួលបន្ទុកសិទ្ធិឯកជន, ឬបុគ្គលិកចុះបញ្ជីនៅពេលណាមួយបាន។